ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០៩០/២១ អអររ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១

ព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តកណ្តាល»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តមបណ្ឌិត ម៉ៅ ធនិរុណា ប្រធានក្រុមប្រឹក្សាខេត្តកណ្តាល**
- **លោក អេង សុចិចិត្រ អភិបាលស្រុកកោះធំ**
- **លោក អ៊ុក ស្រ៊ន មេឃុំសំពៅពូន ស្រុកកោះធំ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

## I. សេចក្តីផ្តើម

ខេត្តកណ្តាលមានផ្ទៃដី សរុប ៣ ២១១,៧៦ គ.ម២ មានក្រុង១ និង១០ស្រុក គ្របដណ្តប់លើ ១១៧ឃុំ និង១០សង្កាត់ និងមានភូមិសរុប ១ ០១០ភូមិ មានប្រជាជនសរុប ១ ២៩១ ៥៨១នាក់ ក្នុងនោះប្រជាពលរដ្ឋប្រកបមុខរបរសំខាន់ៗមានដូចជា កសិកម្ម ៥០,៥% សិប្បកម្ម ១,២% និងសេវាកម្ម ៤៨,៣% បានធ្វើឱ្យសេដ្ឋកិច្ចខេត្តមានការកើនឡើង អត្រាភាពក្រីក្រថយចុះពី ៥,៣៣% (ឆ្នាំ២០១៨) មកត្រឹម ៤,៥៧% (ឆ្នាំ២០១៩) ស្របតាមគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលឱ្យស្ថិតនៅ ក្នុងអត្រាទាបជាង១០%។

## II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

❖ **ក្រុមប្រឹក្សាខេត្ត**

ក្រុមប្រឹក្សាខេត្តបានខិតខំបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ខ្លួនដោយសម្រេចបាននូវលទ្ធផលលើការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច អភិបាលកិច្ចល្អ ក្នុងគោលដៅលើកកម្ពស់គុណភាពសេវាសាធារណៈ កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍លើមូលដ្ឋានដូចខាងក្រោម៖

- ការងារកសិកម្ម៖ ជាវិស័យស្នូលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចខេត្ត ដែលផ្ទៃដីកសិកម្មសរុបមាន ១៤១ ៩៩៦ហិកតា (ស្មើនឹង ៤៣,៦៧% នៃផ្ទៃដីខេត្ត) ក្នុងនោះ ផ្ទៃដីបង្កបង្កើនផលស្រូវ ១០២ ៥៧៨ហិកតា (៧២,២៤%) ផ្ទៃដីដំណាំកសិ-ឧស្សាហកម្ម និងដំណាំរួមផ្សំ ៣៣ ៤៥៧ហិកតា(២៣,៥៦%) និងផ្ទៃដីដំណាំអនុផល ៥ ៩៦១ហិកតា(៤,២%)។
- ការងារសង្គមកិច្ច៖ បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដែលជាលទ្ធផលមានស្ត្រីសរុប ២ ៤៩៣នាក់ និងកុមារ ១ ៤៤៨នាក់ និងបានអនុវត្តកម្មវិធីឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដោយមានគ្រួសារមកផ្ទៀងផ្ទាត់ឈ្មោះ ៣៤ ៨៩០គ្រួសារ។
- វិស័យឧស្សាហកម្ម៖ ខេត្តមានរោងចក្រសហគ្រាសសរុប ៤៥១ វិស័យផលិតសម្លៀកបំពាក់ និងដេរស្បែកជើង សរុបចំនួន ១៤៤ វិស័យធនាគារនិងហិរញ្ញវត្ថុ ចំនួន ១៣៦ វិស័យសិប្បកម្មផលិតឥដ្ឋ ៧៣ ដែលបានផ្តល់ការងារជូនកម្មករសរុបចំនួន ១៣១ ១១៣នាក់ ស្រី ១១១ ៩១៤នាក់។
- វិស័យទេសចរណ៍៖ វិស័យទេសចរណ៍ក្នុងខេត្ត បានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចខេត្ត ស្មើនឹង២៦,៧% នៃចំណូលថវិកាខេត្ត និងបានផ្តល់ការងារមួយផ្នែកធំជូនប្រជាពលរដ្ឋ ក្នុងនោះតំបន់ទេសចរណ៍សំខាន់ៗ រួមមាន ភ្នំព្រះរាជទ្រព្យ ភ្នំប្រសិទ្ធ កៀនស្វាយក្រៅ ស្ពានភ្នំ ស្ពាយលែន ចំការស្នេហ៍ អ្នកតាចិន និងគោលដៅទេសចរណ៍មួយចំនួនទៀត។
- វិស័យរ៉ែ ថាមពល អគ្គិសនី និងទឹកស្អាត៖ ខេត្តមានប្រតិបត្តិករផ្គត់ផ្គង់ និងចែកចាយអគ្គិសនី (រដ្ឋ និងឯកជន) ចំនួន៦៤ ដែលបានផ្គត់ផ្គង់អគ្គិសនីដល់ភូមិទូទាំងខេត្ត ១០១០ភូមិ លើ ២២១ ០៨៦ខ្នងផ្ទះ ស្មើនឹង១០០ % និងមានផលិតកម្ម អាជីវកម្មទឹកស្អាត សរុបចំនួន ៥០មូលដ្ឋាន ក្នុងនោះ ៤៩មូលដ្ឋានជារបស់ឯកជន និង០១មូលដ្ឋាន ជារបស់រដ្ឋាករទឹកស្វយ័តភ្នំពេញ។
- បានប្រជុំសាមញ្ញទៀងទាត់ស្របតាមប្រតិទិនកំណត់ ជានាបានខ្លឹមសារ របៀបវារៈ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបទបញ្ញត្តិក្នុងខ...

- បានរៀបចំកិច្ចប្រជុំវិសាមញ្ញ ដើម្បីពិនិត្យ និងដោះស្រាយបញ្ហាប្រឈមចាំបាច់ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលតម្រូវ។
- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ទៀងទាត់នៅក្នុងអំឡុងត្រីមាសទី៤ នៃឆ្នាំនីមួយៗ ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងបានប្រមូលយកបញ្ហា ទុក្ខកង្វល់ សំណើសំណូមពររបស់មូលដ្ឋានមកពិនិត្យ និងបានចាត់អាទិភាព និងធ្វើការដោះស្រាយតាមសមត្ថកិច្ច។
- ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩៖ បានយកចិត្តទុកដាក់ចំពោះការងារចត្តាឡីស័កតាមច្រកទ្វារអន្តរជាតិ ដោយបានចាត់តាំងឱ្យមានមន្ត្រីសុខាភិបាលប្រចាំការត្រួតពិនិត្យសុខភាពអ្នកដំណើរ នាវិក និយោជិត ឆ្លងដែនតាមច្រកអន្តរជាតិ ជ្រៃធំ និងក្អមសំណ និងបានអនុវត្តវិធានការណ៍ឆ្លើយតបទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ តាមបណ្តាក្រុង ស្រុក ដោយរៀបចំមណ្ឌលចត្តាឡីស័ក សរុបចំនួន ១៨កន្លែង ព្រមទាំងបានចូលរួមបរិច្ចាគថវិកាជាមួយសម្តេចតេជោនាយករដ្ឋមន្ត្រី ទិញវ៉ាក់សាំងការពារជំងឺកូវីដ១៩ ថវិកាសរុបចំនួន ២២៧ ៩០៣ ៩០០រៀល និង៣៩ ១៦៤ដុល្លារ។

### ❖ ស្រុកកោះធំ ខេត្តកណ្ដាល

- ការផ្តល់សេវាសាធារណៈ៖ ការិយាល័យច្រកចេញចូលតែមួយ បានផ្តល់សេវាសាធារណៈលើវិស័យចំនួន១២ ជូនប្រជាពលរដ្ឋសរុបចំនួន៥,៩៧៣នាក់ ក្នុងនោះស្រីចំនួន៣,៥៥៧នាក់ បានចំនួន៥,៩៧៣សេវា, បានធ្វើការវាស់វែង កំណត់ព្រំ និងវិនិច្ឆ័យក្នុងឃុំសំពៅពូន បានចំនួន ៣០៦៦ ក្បាលដី, បានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដល់ម្ចាស់ក្បាលដីដែលបានចុះបញ្ជីរួច នៅភូមិកំពង់ថ្កុល ឃុំសំពៅពូន បានចំនួន ២០៤១ ប័ណ្ណ និងក្នុងឆ្នាំ២០២០ បានធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ បានចំនួន ៤០៥៣ នាក់ ស្រី ៧២ នាក់។
- ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩៖ រដ្ឋបាលស្រុកបានត្រៀមរៀបចំមណ្ឌលចត្តាឡីស័កចំនួន២កន្លែង និងបានរៀបចំឱ្យបងប្អូនប្រជាពលរដ្ឋ ដែលមកពីក្រៅប្រទេសធ្វើចត្តាឡីស័កនៅនឹងមូលដ្ឋានមានចំនួន ១,១៤៤នាក់ ក្នុងនោះធ្វើចត្តាឡីស័កក្នុងមណ្ឌលចត្តាឡីស័ករបស់ស្រុកមានចំនួន២៥នាក់។ ដើម្បីចូលរួមទប់ស្កាត់ការឆ្លងដែនដោយខុសច្បាប់ និងមិនបានធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ គណៈបញ្ជាការឯកភាពស្រុក បានសហការជាមួយកងកម្លាំងការពារព្រំដែន៦០១ នគរបាលការពារព្រំដែន៦០៥ យោធភូមិភាគពិសេស សមត្ថកិច្ចព្រំដែន និងគណៈបញ្ជាការឯកភាពខេត្ត ធ្វើការល្បាត ក្តាប់មុខសញ្ញា និងយាមប្រចាំការ ដើម្បីទប់ស្កាត់ការឆ្លងដែនខុសច្បាប់របស់ប្រជាជននៃប្រទេសទាំងពីរកម្ពុជា-វៀតណាម។

- ការងារព្រំដែន៖ ស្រុកមានច្រកទ្វារចំនួន ០៣គឺ ច្រកទ្វារអន្តរជាតិជ្រៃធំ ច្រកទ្វារតំបន់ព្រែកស្បូវ និងច្រកទ្វារតំបន់ព្រែកជ្រៃ-ព្រែកទន្លា។ ដោយអនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាល និងតាមការណែនាំចង្អុលបង្ហាញពីរដ្ឋបាលខេត្ត រដ្ឋបាលស្រុកបានទប់ស្កាត់ និងលុបបំបាត់ចោលទាំងស្រុងនូវច្រករបៀង និងការដួលដីឱ្យទៅប្រជាពលរដ្ឋវៀតណាមតាមបណ្ដោយព្រំដែនចាប់តាំងពីឆ្នាំ២០១៨មក។

❖ **ឃុំសំពៅពូន ស្រុកកោះធំ**

- ការផ្ដល់សេវាសាធារណៈ៖ បានចុះបញ្ជីកំណើត ចំនួន ៤៥៤ នាក់ ស្រី ២០៧ នាក់, បានចុះបញ្ជីបញ្ជាក់កំណើត ចំនួន ១៦៤ នាក់ ស្រី ៧៩ នាក់, បានចុះបញ្ជីអាពាហ៍ពិពាហ៍ចំនួន ៧៦គូ, បានចុះបញ្ជីមរណភាព ចំនួន ១១៣ នាក់ ស្រី ៥៧ នាក់, បានចុះឈ្មោះបោះឆ្នោតថ្មីចំនួន ៣៥០ នាក់ ស្រី ១៧៥ នាក់, បានធ្វើការវាស់វែងដីធ្លីមានលក្ខណៈជាប្រព័ន្ធបាន ៧ ភូមិ និងបានផ្ដល់ប័ណ្ណកម្មសិទ្ធជូនប្រជាពលរដ្ឋបាន ៣.៣០០ ក្បាលដី និងបានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ ក្នុងអំឡុងពេលជំងឺកូវីដ-១៩ ចំនួន ៥០៧ គ្រួសារ ព្រមទាំងបានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ២ឆ្នាំ បានចំនួន ៥០ នាក់។
- ការងារកសិកម្ម៖ ឃុំសំពៅពូន ជាឃុំមានសក្តានុពលលើវិស័យកសិកម្ម មានផ្ទៃដីបង្កបង្កើនផលស្រូវប្រាំងចំនួន ៤.៥៨៧ ហិកតា និងមានផ្ទៃដីអនុផល មានចំនួន ១០២១ ហិកតា។
- ការងារហេដ្ឋារចនាសម្ព័ន្ធ៖ បានសាងសង់ផ្លូវបេតុងអាមេប្រវែង ៦៣០ម ទីតាំងនៅភូមិក្បាលកោះទៀវ, បានសាងសង់ផ្លូវអំពីបេតុងអាមេប្រវែង ៥៤០ម ទីតាំងគម្រោងភូមិខ្ពប, បានសាងសង់ផ្លូវអំពីបេតុងអាមេប្រវែង ១៧០ម ទីតាំងគម្រោងភូមិខ្ពប, បានសាងសង់ផ្លូវក្រាលកៅស៊ូ ១ខ្សែ (ផ្លូវទៅកាន់ភូមិព្រែកស្បូវ) ប្រវែង ៣,៣០០ម ទទឹង ៧ម និងក្រាលថ្មល្អិត ២.១០០ម ទទឹង ៨ម, បានសាងសង់ផ្លូវអំពីបេតុងអាមេទាំង១១ភូមិ ចំនួន ២៤ខ្សែ សរុបប្រវែង ១២.៣៩៥ ម, បានសាងសង់ផ្លូវបេតុងអាមេប្រវែង ១.៥២១ ម ទីតាំងគម្រោងភូមិជ្រៃធំ។
- ការងារអប់រំ៖ មានសាលាសិក្សា ៧កន្លែង ក្នុងនោះ មានបឋមសិក្សា ៦ កន្លែង មានអាគារ ១៨ខ្នង មាន ៨២ថ្នាក់ គ្រូ ៧៩ នាក់ សិស្ស ២.៩៩៤ នាក់ និងវិទ្យាល័យ ១កន្លែង អាគារ ៧ ខ្នង មាន ៣២ថ្នាក់ គ្រូ ៦៧ នាក់ សិស្ស ១.៨៨២ នាក់។
- ការងារសន្តិសុខសណ្តាប់ធ្នាប់៖ បានផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹង ដើម្បីការពារសុវត្ថិភាពភូមិឃុំ ក្នុងនោះមានកម្លាំងប្រជាការពារ ចំនួន ១១៥ នាក់ សហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាល បានប្រចាំការពេលយប់គ្រប់ភូមិទាំង១១គោលដៅ និងបានសហការជាមួយវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៦០៥ និងកម្លាំងកងការពារព្រំដែនលេខ ៦០១ ការពារការជ្រៀតចូលព្រំដែនខុសច្បាប់របស់ប្រជាជនជិតខាង។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

- បន្តពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង មុខងាររបស់រដ្ឋបាលខេត្ត និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក និងពិនិត្យឡើងវិញនូវមុខងារសំខាន់ៗមួយចំនួន ពាក់ព័ន្ធភាពជាតំណាងរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងមុខងារគាំទ្រដល់ការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន ដើម្បីប្រែក្លាយជារដ្ឋបាលតំបន់ តាមគោលការណ៍រដ្ឋបាលឯកភាព។
- បន្តជំរុញ និងគាំទ្រយន្តការមណ្ឌលអភិវឌ្ឍធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីរាជការក្នុងរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ និងបន្តពង្រឹងសមត្ថភាពគ្រប់គ្រង ចាត់ចែង។
- បន្តផ្តល់ការអភិវឌ្ឍសមត្ថភាពព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយឱ្យបានកាន់តែប្រសើរ ដើម្បីឈានដល់ការផ្តល់សេវាតាមប្រព័ន្ធអនឡាញ ព្រមទាំងជំរុញការអនុវត្តប្រព័ន្ធអេឡិចត្រូនិក ក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខេត្ត។
- បន្តផ្តោតលើការលើកកម្ពស់ការងារចាំបាច់នានា រួមមាន ការងារយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ តាមរយៈការបញ្ជ្រាបកិច្ចការទាំងនេះមកក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្ត ដើម្បីជានាលទ្ធភាពពេញលេញក្នុងការគ្រប់គ្រងធនធានមនុស្ស ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដោយគ្មានការរើសអើង និងឆ្លើយតបនឹងបញ្ហានានាដែលបានកើតមាន បានទាន់ពេលវេលា។

### ❖ ស្រុកកោះធំ ខេត្តកណ្តាល

- បន្តអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព។
- បន្តលើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អ ការកែទម្រង់ប្រព័ន្ធរដ្ឋបាល ដោយពង្រីកវិសាលភាព សេវាកម្មដែលផ្តល់ដោយរដ្ឋបាលស្រុក។
- បន្តកែលំអរការផ្តល់សេវាសាធារណៈ កាត់បន្ថយអំពើពុករលួយ និងបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការផ្តល់មតិយោបល់ និងការរិះគន់ស្ថាបនា។
- បន្តខិតខំរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ នៅតាមបណ្តាផ្លូវ និងទីសាធារណៈក្នុងភូមិសាស្ត្រស្រុកកោះធំ ដើម្បីរក្សាបាននូវបរិស្ថាន។
- បន្តកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយអាជ្ញាធរស្រុកអានភូ ខេត្តអាងយ៉ាងតាមគ្រប់រូបភាព ដើម្បីជំរុញកិច្ចអភិវឌ្ឍន៍តាមព្រំដែន។
- បន្តបង្វិតរដ្ឋបាលឱ្យនៅកៀកជិតនឹងប្រជាពលរដ្ឋ បង្កភាពងាយស្រួលក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាព។

- បន្តផ្សព្វផ្សាយពីវិធានការ ការពារ ទប់ស្កាត់ គ្រប់គ្រង និងប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាល នៃ វីរុសកូវីដ-១៩ ឆ្លើយតបបានទាន់ពេលវេលានៅតាមបណ្តាមូលដ្ឋានភូមិ-សង្កាត់។

❖ **ឃុំសំពៅពូន ស្រុកកោះធំ**

- បន្តយកចិត្តទុកដាក់បម្រើសេវារដ្ឋបាលជូនប្រជាពលរដ្ឋឱ្យបានលឿនរហ័ស និងមិនរើសអើង។
- បន្តការយកចិត្តទុកដាក់ និងខិតខំពង្រឹងការអនុវត្តន៍នូវគោលនយោបាយភូមិ-ឃុំ សង្កាត់ មានសុវត្ថិភាព ទាំង ៧ ចំណុច ជាប្រចាំ។
- ផ្សព្វផ្សាយច្បាប់ជាចំណេះដឹងជូនដល់ប្រជាពលរដ្ឋ សម្រាប់អនុវត្ត។
- បន្តដោះស្រាយវិវាទ និងសម្រុះសម្រួលទំនាស់ជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។
- បន្តរៀបចំកម្មវិធីវិនិយោគសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ក្នុងមូលដ្ឋាន។
- បន្តការផ្សព្វផ្សាយពីវិធានការណ៍ការពារការឆ្លងជំងឺកូវីដ-១៩។
- បន្តការផ្សព្វផ្សាយ អប់រំជូនប្រជាពលរដ្ឋ ឱ្យចូលរួមយល់ដឹងពីការរស់នៅស្អាត ហូបស្អាត និងធ្វើអនាម័យ បរិស្ថានឱ្យបានល្អ។
- ធ្វើការគៀងគររកដៃគូរ អ្នកវិនិយោគ និងសប្បុរសជន ដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានភូមិ-ឃុំ។

## IV. សម្គាល់

ដើម្បីចូលរួមចំណែកក្នុងការប្រែក្លាយតំបន់ព្រំដែនឱ្យក្លាយជាព្រំដែនសន្តិភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ និងដោយមានការគាំទ្រពីក្រសួងស្ថាប័ន អង្គការដៃគូ រដ្ឋបាលខេត្ត ក្រុង ស្រុកបានខិតខំកែលម្អហេដ្ឋារចនាសម្ព័ន្ធ លើកកម្ពស់បរិស្ថាន អនាម័យ នឹងគ្រោងគោរពស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលដើម្បីប្រែក្លាយទីប្រជុំជនជ្រៃធំក្លាយជាទីក្រុងថ្មីរបស់ខេត្តកណ្តាល។ ជាពិសេសរដ្ឋបាលខេត្តបានសហការយ៉ាងល្អក្នុងការថែរក្សាស្ថេរភាព សន្តិសុខសណ្តាប់ធ្នាប់តាមខ្សែបន្ទាត់ព្រំដែន រួមចំណែកពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការមិត្តភាព រវាងកងកម្លាំងសមត្ថកិច្ចឈរជើងនៅព្រំដែននៃប្រទេសទាំងពីរ ដោយឈរលើគោលការណ៍ គោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដី។

ថ្ងៃចន្ទ ១១កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១